GLOBAL CAMPAIGN FOR
EDUCATION
www.campaignforeducation.org

## សប្តាហ៍សកម្មភាព នៃយុទ្ធនាការជាសកលសម្រាប់ការអប់រំ

## ខែមេសា ២០-២៦ ឆ្នាំ២០០៩

### កញ្ចប់រៀបចំផែនការសម្រាប់យុទ្ធនាការ នៃសប្តាហ៍សកម្មភាពជាសកល

# ការអានដ៏ធំមួយ !

## អក្ខរកម្ម របស់យុវជន និងមនុស្សពេញវ័យ
## និងការរៀនសូត្រពេញមួយជីវិត

*អ្នកធ្វើយុទ្ធនាការទាំងអស់ជាទីរាប់អាន,*

គណៈកម្មាធិការរៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំ មានសេចក្តីរីករាយសូមបង្ហាញជូននូវកញ្ចប់ផែនការ GCE សម្រាប់សកម្មភាពសប្តាហ៏ឆ្នាំ ២០០៩។ ដោយសារការចូលរួមផ្តល់គំនិតយោបល់ពីសមាជិករៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំនៅឆ្នាំនេះ ជាពិសេស នៅក្នុងសភាពិភពលោករបស់គណៈកម្មាធិការរៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំ ដែលបានប្រព្រឹត្តិធ្វើឡើងនៅប្រទេស ប្រេសិលកាលពីខែមករាកន្លងមក។ ឆ្នាំនេះ គណៈកម្មាធិការនាយក នៃគណៈកម្មាធិការរៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំ លេខាធិការដ្ឋាន និង ក្រុមរៀបចំផែនការ បានធ្វើការយល់ព្រមលើយុទ្ធសាស្ត្រសម្រាប់ការរៀបចំសប្តាហ៏សកម្មភាពសម្រាប់យុទ្ធនាការជាសកលសម្រាប់ការអប់រំ ឆ្នាំ២០០៩ ដូច្នេះ លោក លោកស្រីនឹងមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំ និងធ្វើផែនការ។

ប្រធានបទសម្រាប់ឆ្នាំនេះគឺ “ អក្ខរកម្ម របស់យុវជន និងមនុស្សពេញវ័យ និង ការរៀនសូត្រពេញមួយជីវិត ” ។ យើងបានបង្កើតឡើងនូវផែនការមួយចំនួន ដែលយើងសង្ឃឹមថានឹងបង្រួបបង្រួមក្រុមអ្នករៀបចំយុទ្ធនាការទាំងអស់នៅជុំវិញពិភពលោក។

នៅក្នុងព្រឹត្តិការសំខាន់ៗថ្នាក់ជាតិ យើងសង្ឃឹមថា សភា/រដ្ឋសភា និងស្ថាប័នដទៃទៀត ត្រូវបានធ្វើការទាក់ទាញដើម្បីបើកទ្វារ/បង្ហាញផ្លូវ ដល់អ្នកសិក្សាដែលជាយុវជន/យុវនារីនៅក្នុងសប្តាហ៏សកម្មភាព។

ជាធម្មតា យើងរៀបចំសកម្មភាពរួមសំខាន់មួយ ដែលនឹងផ្សារភ្ជាប់ក្រុមមូលដ្ឋាន និង ការងារសាលាជាមួយនឹងព្រឹត្តិការជាតិ និងព្រឹត្តិការណ៏ជាសកល។ ឆ្នាំនេះ យើងរៀបចំសៀវភៅរឿង ដែលមានរឿងជាច្រើនបានសរសេរដោយអ្នកនិពន្ធ និងអ្នកគាំទ្រវិស័យអប់រំនៅលើពិភពលោក។ រឿងទាំងអស់នេះផ្តោតលើថាតើការអាននិងការសរសេររបស់គេ បានផ្លាស់ប្តូរការរស់នៅរបស់គេយ៉ាងដូចម្តេច ហើយថាតើការអាន និងការសរសេរនេះអាចផ្លាស់ប្តូរការរស់នៅរបស់មនុស្សរាប់លានដោយរបៀបណា ប្រសិនបើការសន្យាស្តីពីការអប់រំសម្រាប់ទាំងអស់គ្នាត្រូវបានរក្សាទុក។ នៅផ្នែកបញ្ចប់នៃសៀវភៅរឿង ស្នើសុំឱ្យមនុស្សផ្សេងទៀតសរសេរបន្ថែមឈ្មោះរបស់គេ និងសារមួយចំនួនទៀតដើម្បីធានាអះអាងពីសារៈសំខាន់នៃការអាន និង

សរសេរ។ ក្រុមអ្នករៀបចំយុទ្ធនាការត្រូវបានលើកទឹកចិត្តដើម្បីជួយដល់អ្នកដែលមិនចេះអាន និងសរសេរ ដោយការអានរឿងទាំងនោះឱ្យពួកគេស្តាប់ ហើយសួរគេប្រសិនបើគេចង់សរសេរឈ្មោះរបស់គេបន្ថែម ដើម្បីធានាអះអាងអំពីសារៈសំខាន់នៃការអាន និងសរសេរ។

យើងចង់ឱ្យបញ្ជីឈ្មោះអ្នកដែលបានចូលរួម មានចំនួនច្រើនដែលអាចធ្វើទៅបាន ប្រយោជន៍ដើម្បីនៅពេលដែលសារ និងឈ្មោះទាំងនោះត្រូវបានផ្ញើរទៅកាន់អ្នកធ្វើគោលនយោបាយ និងអ្នកនយោបាយនានាបានដឹងពីទំហំនៃការគាំទ្រលើការអប់រំសម្រាប់ទាំងអស់គ្នា។ យើងក៏សូមលើកទឹកចិត្តដល់អ្នកក្នុងការបញ្ចូលអ្នកធ្វើគោលនយោបាយ និងអ្នកនយោបាយនៅក្នុងព្រឹត្តិការណ៍ ដើម្បីឱ្យពួកគេបានរៀនអំពី បញ្ហានៃការអប់រំ និងសារៈសំខាន់នៃការអប់រំសម្រាប់ទាំងអស់គ្នា។ ពាក់កណ្តាលនៃកាលបរិច្ឆេតឆ្នាំ២០១៥ ដើម្បីសម្រេចបានទិសដៅការអប់រំសម្រាប់ទាំងអស់គ្នា ពិភពលោកនៅមានការខ្វះចន្លោះ ហើយទិសដៅទី៤ ស្តីពី អក្ខរកម្ម គឺជាទិសដៅមួយដែលពុំមានការយកចិត្តទុកដាក់ខ្លាំង អាស្រ័យដូចនេះ យើងចង់ធ្វើឱ្យមានសម្ពាធដល់អ្នកនយោបាយជាច្រើនតាមដែលអាចធ្វើបាន អំពីសេចក្តីត្រូវការដែលត្រូវការចាត់វិធានការជាបន្ទាន់។

សាលារៀន និងក្រុមការងារក្នុងមូលដ្ឋានអាចចូលរួមជ្រើសរើសយកសកម្មភាពមួយក្នុងចំណោមសកម្មភាពទាំង៣ ខាងក្រោម:

- អញ្ជើញអ្នកនយោបាយម្នាក់ និងអ្នកធ្វើគោលនយោបាយនានា ទៅធ្វើការប្រមូលផ្តុំមួយដែលមានការអានសៀវភៅ បន្ទាប់មកប្រគល់សៀវភៅ និងបញ្ជីហត្ថលេខាដែលប្រមូលបានដល់ពួកគេ។
- សរសេរបន្ថែមសេចរឿងក្នុងមូលដ្ឋានពីអ្នកដែលមានឈ្មោះល្បីល្បាញ ឬក៏អ្នកដែលខកខាន ឬបានខកខានពុំបានចូលរៀន ទៅក្នុងសៀវភៅរឿង សរសេរបន្ថែមក្នុងតារាងអ្នកគាំទ្រ

ចំពោះសៀវភៅនេះ និងផ្ញើរសៀវភៅនេះ ទៅដល់អ្នកនយោបាយ និង/ឬ អ្នកធ្វើគោលនយោបាយសំខាន់ៗ។

- សិស្ស/និស្សិត និងអ្នករៀននានា អាចប្រើប្រាស់សៀវភៅនេះដើម្បីសរសេររឿងរបស់គេដោយផ្ទាល់ ឬក៏សរសេរម្តងទៀតនៅចុងសាច់រឿងនៃសៀវភៅនេះ បន្ទាប់មកប្រគល់សៀវភៅនេះ និងតារាងអ្នកគាំទ្រទៅដល់មន្ត្រីអប់រំ។

យើងសង្ឃឹមថា ក្រុមការងារនឹងមានលទ្ធភាព ដើម្បីធ្វើឱ្យមានការចូលរួមច្រើនពីសាលារៀន និងថ្នាក់មូលដ្ឋាន។ យើងចង់ធ្វើឱ្យមានការចូលរួមច្រើនពីអ្នកនយោបាយ មនុស្សពេញវ័យ និង កុមារ ដែលនឹងធ្វើឱ្យអ្នកដឹកនាំនៅលើពិភពលោកមានសម្ពាធដើម្បីរក្សាលើការសន្យារបស់ពួកគេ។ យើងក៏សូមស្នើសុំឱ្យក្រុមធ្វើយុទ្ធនាការនៅតាមបណ្តាប្រទេសនានា ព្យាយាមរៀបចំព្រឹត្តិការណ៍សំខាន់មួយ ដែលជាព្រឹត្តិការលើកទឹកចិត្តដល់រដ្ឋាភិបាល ដើម្បីចូលរួមសកម្មភាពលើការអាន និងសរសេរ។ ពាក្យស្លោកសម្រាប់ព្រឹត្តិការណ៍ ថ្នាក់ជាតិគឺ “ **បើកសៀវភៅ បង្ហាញផ្លូវអនាគត** ”។

កញ្ចប់ផែនការនេះមានផ្ទុកព័ត៌មានដែលអ្នកត្រូវការដើម្បីធ្វើការពិចារណានូវគំនិត និងការសំរេចចិត្តចុះឈ្មោះចូលរួមធ្វើយុទ្ធនាការ។ ផែនការនេះផ្តល់ព័ត៌មានពិស្តារពីប្រធានបទប្រចាំឆ្នាំ — *អក្ខរកម្មរបស់យុវជន និងមនុស្សពេញវ័យ និងការរៀនសូត្រពេញមួយជីវិត*។ វាក៏បានរៀបចំអំពីកាលបរិច្ឆេតសំខាន់ៗដែលអាចដឹង នៅពេលណាដែលអ្នកធ្វើសកម្មភាព និង អ្វីដែលអាចរំពឹងថានឹងទទួលបានពីក្រុមអ្នករៀបចំផែនការសប្តាហ៍សកម្មភាពយុទ្ធនាការជាសកលសម្រាប់ការអប់រំ។

ដោយសាពេលវេលា យើងសូមសំណូមពរដល់អ្នករៀបចំយុទ្ធនាការទាំងអស់ ឱ្យធ្វើការចាប់អារម្មណ៏ជាពិសេសទៅលើពេលវេលា ដែលបានស្នើឡើងនៅខាងចុងឯកសារនៃកញ្ចប់ផែនការ ដែលវាជាមធ្យោបាយមួយនាំផ្លូវដើម្បីធានាថា សកម្មភាពសប្តាហ៏ឆ្នាំ២០០៩ នឹងទទួលបានជោគជ័យដ៏ធំមួយ។ ប៉ុន្តែមានដំណាក់កាលសំខាន់ៗខ្លះ ដែលអ្នកត្រូវពិនិត្យមើលៈ

ក) កិច្ចប្រជុំរៀបចំផែនការដំបូង

ខ) ការផ្ញើរត្រឡប់វិញនៃទំរង់ចុះឈ្មោះ

គ) ការស្នើសុំថវិកា

ឃ) ការអនុមតិថវិកាដោយលេខាធិការដ្ឋាន គណៈកម្មាធិការរៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំ

យើងសង្ឃឹមថា លោកអ្នកចូលរួមនៅក្នុងការខិតខំប្រឹងប្រែងរួមគ្នានេះ ដើម្បីបង្កើតព្រឹត្តិការណ៍ពិតប្រាកដមួយនៅក្នុងខែមេសា ជាមួយនឹងអ្នកដឹកនាំ និង អ្នកនយោបាយនៅលើពិភពលោក ដែលផ្តោតលើសារៈសំខាន់នៃអក្ខរកម្មរបស់យុវជន និងមនុស្សពេញវ័យ និងការរៀនសូត្រពេញមួយជីវិត។

យើងសូមថ្លែងអំណរគុណចំពោះការខិតខំប្រឹងប្រែងរបស់អ្នក និង គំនិតយោបល់ស្ថាបនារបស់អ្នក និងសូមជូនពរអ្នកមានជោគជ័យគ្រប់ភារកិច្ចនៅក្នុងដំណាក់កាលរៀបចំផែនការ សម្រាប់សប្តាហ៍សកម្មភាពនៃយុទ្ធនាការជាសកលសម្រាប់ការអប់រំ ឆ្នាំ ២០០៩ នៅក្នុងប្រទេសរបស់អ្នក។

កៃឡាស សាធីយាធិ
ប្រធាន

មូលិយា វ៉ាណានីយាន់ដា
អ្នកសម្របសម្រួលសប្តាហ៍សកម្មភាព

# យុទ្ធនាការជាសកលសម្រាប់ការអប់រំ

## កញ្ចប់ផែនការនៃសប្តាហ៍សកម្មភាពឆ្នាំ២០០៨

## ១, ប្រធានបទ :

### “អក្ខរកម្មរបស់យុវជន និងមនុស្សពេញវ័យ និងការរៀនសូត្រពេញមួយជីវិត”

### ១.១ ពត៌មានពិស្តារអំពីប្រធានបទ

អង្គការ យូនីស្កូ បានធ្វើរបាយការណ៍ថា ការចេះអាននិងសរសេរគឺជា “ទិសដៅមួយដែលពុំសូវបានយកចិត្តទុកដាក់គ្រប់គ្រាន់ក្នុងចំណោមទិសដៅទាំង ៦ នៃការអប់រំសម្រាប់ទាំងអស់គ្នា”។ កម្មវិធីអប់រំជាច្រើនផ្តោតលើការអប់រំបឋម ហើយចំពោះការចេះអាន និងសរសេររបស់មនុស្សពេញវ័យគឺជាករណីមួយដែលពុំមានការយកចិត្តទុកដាក់ ដែលបណ្តាលឱ្យមនុស្សពេញវ័យជាច្រើនមិនចេះអក្សរ។ ភាគច្រើន នៃមនុស្សពេញវ័យដែលមិនចេះអក្សរ គឺត្រូវបានគេរកឃើញនៅក្នុងបណ្តាប្រទេសដែលពុំសូវមានការអភិវឌ្ឍ ហើយស្ត្រីមានចំនួនច្រើនជាងបុរស។[១] យោងទៅតាមទិន្នន័យរបស់វិទ្យាស្ថានស្ថិតិ នៃអង្គការ យូនីស្កូ ថ្មីៗនេះ មានមនុស្សធំពេញវ័យដែលមិនចេះអក្សរប្រមាណ ៧៧៤ លាននាក់ នៅក្នុងពិភពលោក ហើយ៦៤% ជាស្ត្រី។

យោងទៅតាមទិន្នន័យនេះ ស្ថិតិអាចនៅមានដែនកំណត់ ព្រោះវាផ្អែកទៅលើភាពពិតដែលចំនួននៅក្នុងបណ្តាប្រទេសនិមួយៗគឺធ្វើការរាយការណ៍ដោយខ្លួនឯង ដោយមិនផ្អែកលើការអនុវត្តការពិសោធន៍ដោយឯករាជ្យ[២]។ វាមានជំនឿជាក់ថា តួលេខនេះនឹងខ្ពស់ជាងនេះទៅទៀត។

[1] See UNDP Human Development Report 2007/8
[2] See UNESCO Institute for Statistics at http://www.uis.unesco.org/ev.php?URL_ID=6401&URL_DO=DO_TOPIC&URL_SECTION=201

សំខាន់បំផុតគឺការចេះអាន និងសរសេរ ដែលការស្រាវជ្រាវបានបង្ហាញថា នៅក្នុងបណ្តាប្រទេសមួយចំនួន កុមារដែលមានកំណើតជាមួយនឹងមាតាដែលមិនចេះអក្សរគឺមានចំនួន ៥០% ពិបាកនឹងសង្គ្រោះឱ្យផុតពីអាយុ ៥ឆ្នាំ។ ជាងនេះទៅទៀត ការចេះអាន និងសរសេររបស់មនុស្សពេញវ័យគឺគន្លឹះ ដើម្បីសម្រេចបានការអប់រំជាសកល ព្រោះថាមនុស្សធំដែលចេះអាន និងសរសេរកម្រនឹងចិញ្ចឹមកុមារដែលមិនចេះអក្សរ។

និយមន័យនៃអក្ខរកម្មគឺមានការវិវត្តគ្រប់ពេលវេលា។ មុខងារនៃអក្ខរកម្មត្រូវបានគេឱ្យនិយមន័យថាជាសមត្ថភាព "អាននិងសរសេរដោយយល់ពីប្រយោគធម្មតា ដ៏ខ្លីមួយ អំពីជីវិតរស់នៅប្រចាំថ្ងៃ "។[៣] ទោះជាយ៉ាងណាក៏ដោយ ការឱ្យនិយមន័យដ៏តូចនេះគឺសម្រាប់តែជាការ បង្រួមអត្ថន័យនៅក្នុងរដ្ឋធម្មនុញ្ញរបស់យុទ្ធនាការជាសកលសម្រាប់ការអប់រំតែប៉ុណ្ណោះ។ ការឱ្យនិយមន័យ ដែលមានលក្ខណៈយកបានគឺ អក្ខរកម្ម : " ការចេះអាន និងសរសេរ និងប្រើប្រាស់លេខ ទទួលព័ត៌មាន បញ្ចេញគំនិតយោបល់ ធ្វើសេចក្តីសម្រេចចិត្ត និងដោះស្រាយបញ្ហានានា ដូចជាសមាជិកគ្រួសារ កម្មករ/អ្នកធ្វើការ ប្រជាពលរដ្ឋ និង អ្នករៀនសូត្រពេញមួយជីវិត "។

អក្ខរកម្ម ពាក់ពន្ធ័នឹងការរៀនជាប់លាប់ ដើម្បីធ្វើឱ្យបុគ្គលខ្លួនឯង សម្រេចបានគោលបំណងរបស់ខ្លួន អភិវឌ្ឍចំណេះដឹងផ្ទាល់ខ្លួននិងសក្តានុពល និងចូលរួមពេញលេញនិងទូលំទំលាយនៅក្នុងសង្គម។[៤] វាត្រូវបានគេធ្វើការអង្កេតផងដែរថាមានការកើនឡើង ការទំនាក់ទំនងក្នុងពាណិជ្ជកម្ម ឬសង្គម ជាទូទៅតម្រូវឱ្យមានសមត្ថភាពប្រើប្រាស់កុំព្យូទ័រ និងបច្ចេកវិទ្យាព័ត៌មានផ្សេងទៀត ដូច្នេះហើយ និយមន័យនៃអក្ខរកម្មអាចពង្រីកដើម្បីបញ្ចូលចំណុចនេះ។[៥]

---

[3] UNESCO (2006) " Literacy: The Core of EFA," EFA Global Monitoring Report.
[4] http://en.wikipedia.org/wiki/Literacy
[5] See Curriculum Framework for Adult Literacy in Scotland accessed on 25th May, 2008

យុទ្ធនាការជាសកលសម្រាប់ការអប់រំ ឱ្យនិយមន័យការអាន និងសរសេរ គឺអំពី “ ការទទួលបាន និង ប្រើប្រាស់ជំនាញនៃការអាន ការសរសេរ និងលេខ និងអភិវឌ្ឍទៅជាប្រជាពលរដ្ឋសកម្ម លើកកម្ពស់សុខភាព និងការចិញ្ចឹមជីវិត និងសមភាពយេនឌ័រ ។[៦]

ប្រធានបទឆ្នាំនេះក៏លើកឡើងផងដែរអំពី អក្ខរកម្មរបស់យុវជន។ ហេតុដូច្នេះហើយ បានជាត្រូវឱ្យមានការឱ្យនិយមន័យពី**យុវជន**។ សម្រាប់ប្រើប្រាស់ក្នុងគោលបំណងស្ថិតិ អង្គការសហប្រជាជាតិបានឱ្យនិយមន័យយុវជនគឺជា “មនុស្សមានអាយុពី ១៥ឆ្នាំ ទៅ ២៤ឆ្នាំ ដោយពុំបានវិនិច្ឆ័យទៅនឹងនិយមន័យផ្សេងទៀត ដែលបង្កើតឡើងដោយបណ្តាប្រទេសផ្សេងៗឡើយ ” ។[៧] សម្រាប់គោលបំណងនៃផែនការនេះ យើងនឹងទទួលយកនូវនិយមន័យរបស់អង្គការសហប្រជាជាតិ។

## ២. សកម្មភាពៈ

យើងបានបង្កើតនូវផែនការមួយដែលទាក់ទាញគឺ **ការអានដ៏ធំមួយ** ដែលយើងសង្ឃឹមថានឹងបង្រួបបង្រួមអ្នកធ្វើយុទ្ធនាការជាសកលសម្រាប់ការអប់រំនៅជុំវិញពិភពលោក។ យើងមានសៀវភៅរឿងមួយ មានសាច់រឿងច្រើន ដែលបានសរសេរដោយអ្នកនិពន្ធល្បីល្បាញមួយចំនួនធំ និងអ្នកធ្វើការតស៊ូមតិ អំពីការអប់រំនៅក្នុងពិភពលោក។ សាច់រឿងទាំងអស់នេះផ្តោតលើ តើការអាននិងសរសេរអាចផ្លាស់ប្តូរជីវិតរស់នៅរបស់គេដោយរបៀបណា ហើយតើវាអាចផ្លាស់ប្តូរជីវិតរស់នៅរបស់ប្រជាជនរាប់លាននាក់ដោយរបៀបណា ប្រសិនជាការសន្យានៃការអប់រំសម្រាប់ទាំងអស់គ្នាត្រូវបានរក្សាទុក។ នៅចុងបញ្ចប់នៃសៀវភៅរឿងនេះ នឹងសុំឱ្យមនុស្សនានាបន្ថែមឈ្មោះរបស់គេ និងសារនានា ដើម្បីបញ្ជាក់អំពីសារៈសំខាន់នៃការអាន និងសរសេរ។

---

[6] Benchmark 1, GCE/AA *Writing the Wrongs: International Benchmarks on Adult Literacy*(2005) 15
[7] This definition was arrived at during preparations for the International Youth Year (1985) and endorsed by the UN General Assembly (see A/36/258) and Resolution 36/28 1981)

យើងចង់ឱ្យបញ្ជីឈ្មោះអ្នកដែលបានចូលរួម ឱ្យមានចំនួនច្រើនតាមដែលអាចធ្វើបាន ប្រយោជន៍ដើម្បីឱ្យនៅពេលដែលឈ្មោះ និងសារទាំងអស់ត្រូវបានផ្ញើរទៅដល់អ្នកធ្វើគោលនយោបាយ និងអ្នកនយោបាយ នៅក្នុងតំបន់របស់អ្នក ឱ្យគេបានដឹងអំពីទំហំនៃការគាំទ្រសកម្មភាព ដើម្បីរក្សានូវកិច្ចសន្យារបស់ពួកគេស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា។

យើងក៏លើកទឹកចិត្តឱ្យក្រុមអ្នកធ្វើយុទ្ធនាការ អញ្ជើញអ្នកធ្វើគោលនយោបាយ និងអ្នកនយោបាយនៅក្នុងមូលដ្ឋានដើម្បីចូលរួមនៅក្នុងព្រឹត្តិការណ៍ ធ្វើដូចនេះ ពួកគេអាចទទួលព័ត៌មានដោយផ្ទាល់អំពីវិបត្តិនៃការអប់រំ និងសារៈសំខាន់នៃការអប់រំសម្រាប់ទាំងអស់គ្នា។ ឥឡូវនេះ យើងបានធ្វើដំណើរជាងពាក់កណ្តាលផ្លូវនៃកាលបរិច្ឆេតកំណត់ឆ្នាំ ២០១៥ សម្រាប់ការសម្រេចបានការអប់រំសម្រាប់ទាំងអស់គ្នា ហើយពិភពលោកកំពុងតែឃ្លាតចេញពីគោលដៅនេះ world is way off track ។ គោលដៅទី ៤ ស្តីអំពីអក្ខរកម្ម គឺពុំសូវមានការយកចិត្តទុកដាក់ ហេតុដូច្នេះហើយ យើងចង់ដាក់សម្ពាធដល់អ្នកនយោបាយឱ្យបានច្រើននាក់តាមដែលអាចធ្វើបាន អំពីតម្រូវការនៃការចាត់វិធានការជាបន្ទាន់។

សាលារៀន និងក្រុមការងារក្នុងមូលដ្ឋាន អាចចូលរួមក្នុងសកម្មណាមួយ នៃសកម្មភាពខាងក្រោមៈ

- អញ្ជើញអ្នកនយោបាយ/អ្នកធ្វើគោលនយោបាយម្នាក់ទៅចូលរួមនៅក្នុងកន្លែងប្រមូលផ្តុំដែលមានការអានសៀវភៅ បន្ទាប់មកប្រគល់ជូនសៀវភៅ និងបញ្ជីហត្ថលេខាដែលប្រមូលបាន។
- ដោយសរសេរបន្ថែមសេចរឿងក្នុងមូលដ្ឋានពីអ្នកដែលមានឈ្មោះល្បី ឬអ្នកសិក្សាពេញវ័យទៅនឹងសៀវភៅរឿង សរសេរបន្ថែមតារាង អ្នកគាំទ្រចំពោះសៀវភៅនេះ និងផ្ញើរសៀវភៅនេះ ទៅដល់អ្នកនយោបាយ និង/ឬ អ្នកធ្វើគោលនយោបាយសំខាន់ៗ។
- សិស្ស/និស្សិត និងអ្នករៀននានា អាចប្រើប្រាស់សៀវភៅនេះដើម្បីសរសេររឿងរបស់គេសរសេរម្តងទៀតនៅចុងសាច់រឿងនៃសៀវភៅនេះ ក្នុងបែបប្រកួតប្រជែងសរសេរសាច់រឿង និងបង្ហាញរឿងផ្ទាល់ខ្លួនរបស់គេ ដោយមានតារាងអ្នកគាំទ្រ ជូនទៅអ្នកនយោបាយ។

យើងសង្ឃឹមថា ក្រុមអ្នករៀបចំយុទ្ធនាការថ្នាក់ជាតិនឹងមានលទ្ធភាពប្រមូលផ្តុំសាលារៀន និងក្រុមអ្នកមូលដ្ឋានឱ្យមានការចូលរួមបានច្រើន តាមដែលអាចធ្វើបាន។ យើងចង់ឱ្យមានការចូលរួមបានច្រើនពីអ្នកនយោបាយ មនុស្សពេញវ័យ និងកុមារ ដែលថ្នាក់ដឹកនាំនៅលើពិភពលោកបានត្រូវគេជម្រុញឱ្យរក្សានូវការសន្យារបស់ពួកគេស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា។ យើងក៏ស្នើសុំឱ្យអ្នកធ្វើយុទ្ធនាការនៅតាមបណ្តាប្រទេស ព្យាយាមរៀបចំព្រឹត្តិការសំខាន់ស្តីពីអក្ខរកម្ម ដែលវាជាការលើកឡើងដ៏សំខាន់ ដែលលើកទឹកចិត្តដល់រដ្ឋាភិបាល ឱ្យធ្វើការខិតខំប្រឹងប្រែងថែមទៀតចំពោះអក្ខរកម្ម។

## សកម្មភាពផ្សេងទៀតដែលត្រូវអនុវត្តដោយក្រុមអ្នកធ្វើយុទ្ធនាការ

យើងសូមស្នើសុំដល់ក្រុមអ្នកធ្វើយុទ្ធនាការ បង្កើតឱ្យមានដំណាក់កាល ឬជំហានច្រើនផ្សេងទៀតធ្វើយ៉ាងណាឱ្យមានមនុស្សចូលរួមច្រើននៅក្នុងសប្តាហ៍សកម្មភាព ហើយសង្ឃឹមយ៉ាងមុតមាំថា នឹងទទួលបានលទ្ធផលកើនឡើងថែមទៀត ចំពោះសកម្មភាពរបស់យើងទៅដល់អ្នកធ្វើគោលនយោបាយនានា។

ក. បញ្ចុះបញ្ចូលក្រុមអ្នកចូលរួម ដើម្បីបំពេញនូវទម្រង់បែបបទពីសកម្មភាព និង ផ្ញើរត្រឡប់ជូនមកវិញ។ ធ្វើដូចនេះដើម្បីដឹងថា តើអ្នកណាខ្លះនឹងចូលរួមធ្វើយុទ្ធនាការ ហើយចំពោះអ្នកដែលចង់បានព័តិមានបន្ថែម យើងអាចផ្ញើរព័តិមានដល់ពួកគេក្នុងពេលវេលាសំខាន់ណាមួយសម្រាប់យុទ្ធនាការ របស់អ្នកនៅពេលបន្ទាប់ក្នុងឆ្នាំនោះ។ ប្រសិនបើយើងអាចប្រមូលព័តិមានបានពិស្តារ អំពីការទំនាក់ទំនង " ជាពិសេស អ៊ីម៉ែល " ពី Global Readathon នោះយើងនឹងអាចបង្កើនភាពខ្លាំង និងទទួលបានលទ្ធផលច្រើននៃយុទ្ធនាការរបស់យើង។ ទម្រង់បែបបទផ្សេងៗ ដូចជា លិខិតថ្លែងអំណរគុណនឹងមានភ្ជាប់ជូនមកជាមួយនឹងកញ្ចប់ធនធានសម្ភារៈ ក៏ដូចជាទំរង់មួយចំនួនផ្សេងទៀត ដែលយើងផ្តល់ជូន សម្រាប់ក្រុមធ្វើយុទ្ធនាការថ្នាក់ជាតិណាមួយ ដែលមានការពិបាកក្នុងការទទួល បន្ទាប់ពីសប្តាហ៍សកម្មភាពនៃយុទ្ធនាការជាសកលសម្រាប់ការអប់រំ។

ខ.  សូមរក្សាគល់បញ្ជីនៃចំនួនអ្នកចូលរួមទាំងអស់ ដែលបានចូលរួមនៅក្នុង Global Readathon សម្រាប់បញ្ជូនទៅលេខាធិការដ្ឋាន យុទ្ធនាការជាសកលសម្រាប់ការអប់រំ បន្ទាប់ពីធ្វើយុទ្ធនាការ ។

គ. យើងនឹងធ្វើការអង្កេតលទ្ធភាពនៃការប្រើប្រាស់សារតាមរយៈទូរសព្ទ័នៅឆ្នាំនេះ ។ យើងនឹងរុករកការរៀបចំលេខទូរសព្ទ័សម្រាប់យុទ្ធនាការទូទៅមួយ ដើម្បីឱ្យប្រជាជនផ្ញើរសារបញ្ជាក់ថា ពួកគេគាំទ្រ Global Readathon ហើយចុះហត្ថលេខាគាំទ្រ ។ បន្ទាប់មកយើងនឹងសរសេរទៅក្រុមអ្នករៀបចំយុទ្ធនាការទាំងអស់ថាយើងអាចធ្វើបានដោយដូចម្តេច នៅក្នុងខែមេសា ឆ្នាំ២០០៩ ។

## ១. ពាក្យស្លោក

យើងស្នើរសុំឱ្យមានពាក្យស្លោកពីរសម្រាប់ប្រើប្រាស់ក្នុងសប្តាហ៏សកម្មភាពជាសកល ។ ពាក្យស្លោកមួយទាក់ទងទៅសកម្មភាព និង ពាក្យស្លោកមួយផ្សេងទៀតទាក់ទងទៅនឹងការទាមទារសំខាន់ៗ ។

ពាក្យស្លោកទាំងនេះនឹងត្រូវបានប្រើប្រាស់នៅលើបដា និងផ្ទាំងរូបភាព ។ល ។

- សកម្មភាព: **ការអានដ៏ធំមួយ**
- ការទាមទារ: " **សិទ្ធិទទួលបានការអាន** "
- យើងនឹងសុំឱ្យអ្នករៀបចំយុទ្ធនាការថ្នាក់ជាតិ រៀបចំវេទិការថ្នាក់ជាតិមួយ ក្រោមប្រធានបទ " **បើកសៀវភៅ បង្ហាញផ្លូវអនាគត** "

ទាំងនេះជាពាក្យស្លោក ដែលគណៈកម្មាធិការរៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំនឹងប្រើប្រាស់នៅលើសម្ភារៈមួយចំនួន និងនៅក្នុងសារព័ត៌មាន ។ សម្រាប់ពាក្យស្លោកនៅក្នុងសប្តាហ៏សកម្មភាព អ្នកអាចប្រើប្រាស់វាទៅលើសម្ភារៈដែលអ្នកចង់ប្រើ ។

## ២, សារសំខាន់ៗ សំណួរ និងចម្លើយ

### ៤.១ តើសកម្មភាពអ្វីខ្លះដែលបានស្នើឡើងសម្រាប់សប្តាហ៍សកម្មភាពជាសកល ឆ្នាំ២០០៩?

យើងនឹងព្យាយាមធ្វើយ៉ាងណាឱ្យមានមនុស្សចូលរួមច្រើននៅក្នុងសកម្មភាព **ការអានដ៏ធំមួយ** នៅទូទាំងពិភពលោក តាមដែលអាចធ្វើទៅបាន — នេះមានន័យថា អានសៀវភៅរឿង និងបន្ថែមឈ្មោះរបស់គេ បន្ទាប់ពីអានដើម្បីអះអាងលើសារៈសំខាន់នៃអក្ខរកម្ម។ យើងលើកទឹកចិត្តសាលារៀន និងក្រុមផ្សេងៗទៀតដើម្បីបើទ្វាររបស់គេដល់អ្នករៀន អ្នកនយោបាយ និងអ្នកសារព័ត៌មាន នៅក្នុងព្រឹត្តិការណ៍ការអានដ៏ធំមួយ។ ប្រសិនបើពុំអាចធ្វើបានទេ ពេលនោះសាលារៀន និងក្រុមផ្សេងៗគួរតែផ្ញើរសៀវភៅរឿង ឈ្មោះ និង សារផ្សេងៗទៀតទៅអ្នកនយោបាយ (ផ្ញើរដោយផ្ទាល់ ឬតាមរយៈក្រុមរៀបចំយុទ្ធនាការថ្នាក់ជាតិ តាមដែលអ្នកពេញចិត្ត) ដោយមានហត្ថលេខា ដែលយើងចង់ឱ្យគេអនុវត្ត ដើម្បីបញ្ចប់ការមិនចេះអក្សរ! សៀវភៅនេះនឹងមានការណែនាំមេរៀនដោយមានសំណើរផ្សេងៗ ពីរបៀបប្រើប្រាស់សៀវភៅ ដោយមានមេរៀនដែលបានរៀបចំឡើង។ ការណែនាំនេះនឹងមាននៅក្នុងកញ្ចប់ធនធាន ដែលផ្ញើរទៅតាមបណ្តាប្រទេសដែលរៀបចំយុទ្ធនាការ។

នៅថ្នាក់ជាតិ យើងសង្ឃឹមថា ស្ថាប័នល្បីៗជាច្រើន ដូចជា រដ្ឋសភា និងតំណាងរាស្ត្រ នឹងបើកទ្វាររបស់គេសម្រាប់អ្នករៀន និងអនុញ្ញាតិឱ្យពួកគេធ្វើជាអ្នករៀបចំព្រឹត្តិការណ៍សម្រាប់ **ការអានដ៏ធំមួយ**។ ការអំពាវនាវឱ្យបើកទ្វារក៏សមស្របជាមួយនឹងយុទ្ធនាការ ដែលទាមទារថា ការអប់រំគឺជាការរំដោះ ឬជាការរួចផុត,,,។

### ៤.២. តើការរីកចំរើនខ្លះដែលបានធ្វើ?

ចាប់តាំងពីយុទ្ធនាការជាសកលសម្រាប់ការអប់រំ ចាប់ផ្តើម មានកុមារចំនួនជាង៤០លាននាក់ បានចូលរៀនសាលា។ ចំនួនកុមារដែលនៅក្រៅសាលាមានការធ្លាក់ចុះទៅ ៧២លាននាក់ និងមនុស្សពេញវ័យ

ដែលមិនចេះអក្សរធ្លាក់ចុះទៅ៧៧៤លាននាក់។ ទោះជាយ៉ាងណាក៏ដោយ ទិសដៅទី ៤ នៃអក្ខរកម្មនៅតែជាទិសដៅមួយដែលពុំមានការយកចិត្តទុកដាក់ក្នុងចំណោមទិសដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា។ ប្រទេសជាច្រើនមិនមានកម្មវិធីអក្ខរកម្ម ដែលឱ្យមនុស្សពេញវ័យនិងយុវជន ដែលមិនទាន់មានឱកាសរៀនពីការអាន និង សរសេរ និងនៅមិនទាន់មានកម្មវិធីសិក្សាថ្នាក់ដំបូង។

## ៤.៣. តើអ្វីដែលត្រូវស្នើសុំឱ្យសាលា និងក្រុមអ្នករៀបចំយុទ្ធនាការមូលដ្ឋានត្រូវធ្វើ?

ចូលរួមនៅក្នុង **ព្រឹត្តិការណ៍ដ៏ធំមួយ**។ អញ្ជើញអ្នកនយោបាយម្នាក់ (ឬប្រធានសហគមន៍) អ្នកសារព័ត៌មាន និង អ្នករៀនពេញវ័យទៅក្នុងសាលា ឬក្រុមរបស់អ្នក នៅក្នុងកំឡុងសប្ដាហ៍សកម្មភាពជាសកលសម្រាប់ការអប់រំ។ អ្នកនយោបាយ និងអ្នកសារព័ត៌មាននឹងអានសៀវភៅរឿង ពីសៀវភៅរឿងដែលបានសរសេរដោយកុមារ និងអ្នករៀននានា អំពីសារៈសំខាន់នៃការអប់រំសម្រាប់ទាំងអស់គ្នា និង បញ្ហានានារបស់យុវជន និងមនុស្សពេញវ័យដែលមិនចេះអក្សរ។ បន្ទាប់ពីអាន អ្នកសារព័ត៌មានក្នុងស្រុក អ្នកនយោបាយប្រធានសហគមន៍ ឬគ្រូបង្រៀន នឹងត្រូវបានសួរដើម្បីធ្វើការបញ្ជាក់ពីការចូលរួមនៅក្នុង **ព្រឹត្តិការណ៍ដ៏ធំមួយ** និងសារនានាដែល នឹងត្រូវផ្ញើរទៅប្រមុខរដ្ឋដោយផ្ទាល់ ឬតាមរយៈអ្នករៀបចំយុទ្ធនាការថ្នាក់ជាតិ (តាមមធ្យោបាយណាដែល អ្នកចូលចិត្ត)។

## ៤.៤. តើអ្នកនយោបាយណាមួយនឹងត្រូវធ្វើការអញ្ជើញ?

យើងលើកទឹកចិត្តដល់សាលា និងក្រុមធ្វើយុទ្ធនាការ ដើម្បីអញ្ជើញអ្នកនយោបាយណា ដែលគេគិតថាមានប្រយោជន៍ដើម្បីធ្វើឱ្យមានឥទ្ធិពល។ ការអញ្ជើញ គួរតែធ្វើការជ្រើសរើសសមាជិករដ្ឋសភា សមាជ ឬក៏តំណាងរាស្ត្រ។ វាគួរតែមានមន្ត្រីអប់រំថ្នាក់ក្នុងមូលដ្ឋាន ឬក៏ជាប្រធានសហគមន៍ បុគ្គលណាម្នាក់ដែលអាចធ្វើឱ្យមានឥទ្ធិពលដល់ការអនុវត្ត ការអប់រំសម្រាប់ទាំងអស់គ្នា ជាពិសេសទិដៅទី៤ នៃការអប់រំសម្រាប់ទាំងអស់គ្នា នៅក្នុងប្រទេសរបស់អ្នកគួតែត្រូវផ្ដោតការយកចិត្តទុកដាក់.

## ៤.៥. តើអ្នកអាចធ្វើអ្វីផ្សេងទៀត?

យើងលើកទឹកចិត្តដល់អ្នកដើម្បីធ្វើការស្ទាបស្ទង់នៅក្នុងសហគមន៍របស់អ្នក ដូចជាការគូសផែនទីការសម្ភាសន៍ ឬក៏រូបភាពរបស់កុមារ និងមនុស្សធំពេញវ័យ ដែលមិនចេះអាន និង/ឬសរសេរ។ គេអាចគូគំនូរ ឬសរសេរសាច់រឿងអំពីជីវិតឪពុកម្តាយ ឬមិត្តភ័ក្តិរបស់គេ ប្រសិនបើគេមិនចេះអាន និងសរសេរ។ នៅពេលដែលប្រមូលសាច់រឿងពីមនុស្សដែលមិនចេះអក្សររួច និងសរសេរជារបាយការណ៍មួយ លទ្ធផលទាំងអស់នេះនឹងត្រូវប្រគល់ ឬផ្ញើរទៅអ្នកនយោបាយ (ឬប្រធានសហគមន៍)។

ព័តិមានពិស្តារអំពីសកម្មភាពផ្សេងទៀតនឹងមាននៅក្នុងខែ កញ្ញា ដែលជាផ្នែកមួយនៃកញ្ចប់ធនធានដែលត្រូវផ្ញើរជូនក្រុមអ្នកធ្វើយុទ្ធនាការ។

## ៤.៦. តើយើងសុំឱ្យអ្នកធ្វើយុទ្ធនាការថ្នាក់ជាតិធ្វើអ្វីខ្លះ?

យើងសុំឱ្យអ្នកធ្វើយុទ្ធនាការថ្នាក់ជាតិ និងអ្នកធ្វើយុទ្ធនាការអប់រំ ចូលរួមការខិតខំប្រឹងប្រែងដើម្បីធ្វើយ៉ាងណាឱ្យមានការចូលរួមច្រើនពីអ្នកនយោបាយ ដែលជាផ្នែកមួយនៃការផ្លាស់ប្តូរ និងលើកកម្ពស់សម្រាប់អក្ខរកម្មរបស់យុវជន និងមនុស្សធំពេញវ័យ និងការរៀនពេញមួយជីវិត។ បន្ថែមទៅលើការរៀបចំផែនការផ្សេងៗ ដែលអ្នកធ្វើនៅក្នុងប្រទេសរបស់អ្នក យើងសូមអញ្ជើញអ្នក ដើម្បីៈ

*រៀបចំព្រឹត្តិការណ៍ថ្នាក់ជាតិមួយ។ ព្រឹត្តិការណ៍នេះត្រូវធ្វើនៅក្នុងអាគាររបស់រដ្ឋាភិបាល ដែលមានអ្នកនយោបាយសំខាន់ៗចូលរួម ដូចជា នៅក្នុងអាគារតំណាងរាស្ត្រ ដែលជាកន្លែងដែលអាចបញ្ជាក់បង្ហាញថា* ***" បើកសៀវភៅ បន្ថាញផ្លូវអនាគត "*** *។*

ក្រុមអ្នករៀបចំយុទ្ធនាការត្រូវបានលើកទឹកចិត្តដើម្បីៈ

- អញ្ជើញប្រមុខរដ្ឋ ឬ រដ្ឋមន្ត្រីហិរញ្ញវត្ថុ ទៅអាគារសាធារណៈ ដូចជាអាគារតំណាងរាស្ត្រ ដែលទ្វារបានបើកសម្រាប់អ្នករៀន ហើយព្រឹត្តិការណ៍ **អាន** ថ្នាក់ជាតិនឹងធ្វើនៅទីនោះ។

- អញ្ជើញអ្នកសារព័ត៌មានទៅជាមួយ ប្រយោជន៍ដើម្បីឱ្យមានព្រឹត្តិការណ៍សារព័ត៌មានធំមួយដែលមានការផ្សព្វផ្សាយទូលំទូលាយ ។
- បង្ហាញដល់ពួកគេអំពីស្ថានភាពនៃគុណភាពអប់រំនៅក្នុងប្រទេសរបស់ ប្រយោជន៍ដើម្បី ឱ្យអ្វីដែលអ្នកទាមទារមានលក្ខណៈច្បាស់ ចំពោះប្រមុខរដ្ឋ ឬ រដ្ឋមន្ត្រីហិរញ្ញវត្ថុ និងក្រុមអ្នកសារព័ត៌មាននានា ។

*ទំនាក់ទំនងជាមួយអ្នកនិពន្ធក្នុងស្រុក អ្នកមានឈ្មោះល្បីល្បាញ និងមនុស្សដែលមានឥទ្ធិពល ដើម្បីសរសេររឿង ឬ ធ្វើការសម្ភាសន៍ជាមួយពួកគេ ដើម្បីឱ្យសាច់រឿងអាចត្រូវបានដាក់បញ្ចូលទៅក្នុងសៀវភៅថ្នាក់ជាតិ ។ (រឿងទាំងនោះអាចជារឿងប្រឌិត ឬសំអាងទៅលើបទពិសោធន៍ ឬក៏អំពីនរណាម្នាក់ដែលគេបានជួប ដូចជា មនុស្សជំទង់ម្នាក់ដែលកំពុងរៀនអាន និងសរសេរ) ។*

### ៤.៧. តើមានគំនិតអ្វីផ្សេងទៀតដែលអាចមានប្រយោជន៍ដល់អ្នករៀបចំយុទ្ធនាការ?

មានគំនិតយោបល់ជាច្រើន ដែលអាចធ្វើឱ្យសកម្មភាពសប្តាហ៍ជាសកលមានភាពរំជើបរំជួល ។

*ចំរៀង*

អ្នករៀបចំយុទ្ធនាការថ្នាក់ជាតិអាចផលិតចម្រៀងអំពីអក្ខរកម្ម ដែលអាចច្រៀងដោយសមាជិកសហគមន៍ ក៏ដូចជាសាលារៀននានានៅក្នុងប្រទេសរបស់អ្នក ។ ចម្រៀងនេះនឹងឆ្លុះបញ្ចាំងពីតម្រូវការអក្ខរកម្មនៃប្រទេសមួយ ហើយវាអាចយកមកច្រៀងនៅក្នុងការរៀបចំព្រឹត្តិការណ៍ ។

*ការប្រមូលករណីសិក្សា និង អ្នកនាំពាក្យ*

ចំណុចសំខាន់មួយទៀត គឺការអនុវត្តដែលបានធ្វើកាលពីយុទ្ធនាការមុនៗ ដើម្បីប្រមូលករណីសិក្សាក៏ដូចជាមនុស្សនានា ដែលគាំទ្រអ្នកក្នុងការអំពាវនាវសម្រាប់អក្ខរកម្ម និងការរៀនសូត្រពេញមួយជីវិត ។

ប្រមូលសាច់រឿងក្នុងមូលដ្ឋានដែលមានការទាក់ទាញស្តីពីអក្ខរកម្ម។ តើមានមនុស្សពេញវ័យ និង យុវជនប៉ុន្មាននាក់ ដែលមិនចេះអក្សរនៅក្នុងសហគមន៍របស់អ្នក ហើយមានប៉ុន្មានអ្នកស្ម័គ្រចិត្តនិយាយអំពីបទពិសោធន៍របស់គេ? សូមធ្វើការចែករំលែកសាច់រឿងទាំងអស់នោះ នៅក្នុងសប្តាហ៍សកម្មភាពជាសកលសម្រាប់ការអប់រំ។ សូមព្យាយាម ហើយកំណត់យ៉ាងហោចណាស់ក៏បានម្នាក់ពីមូលដ្ឋានរបស់អ្នក និងត្រូវចងចាំថា សាច់រឿងណាដែលមានលក្ខណៈល្អជាង គឺមានការទាក់ទាញខ្លាំងពីអ្នកសារព័ត៌មាន ដូចនេះវាធ្វើឱ្យមានការផ្សព្វផ្សាយបានទូលំទូលាយ។ បើអាចធ្វើទៅបាន សូមព្យាយាមប្រើប្រាស់ករណីសិក្សាណាដែលមានការទាក់ទាញ រួមមាន:

- មនុស្សពេញវ័យដែលបានទទួលផលប្រយោជន៍ពីកម្មវិធីអក្ខរកម្មមនុស្សពេញវ័យ នៅក្នុងប្រទេសរបស់អ្នក។
- មនុស្សពេញវ័យដែលមិនចេះអាន និងសរសេរ និងបទពិសោធន៍ដែលគេមានចំពោះការមិនចេះអក្សរ។
- សាច់រឿងរបស់កុមារ តើជីវិតរបស់គេដូចម្តេច ប្រសិនបើឪពុកម្តាយរបស់គេមិនចេះអក្សរ។
- អ្នកមានឈ្មោះល្បីល្បាញក្នុងមូលដ្ឋាន អំពីជីវិតរបស់គេដូចម្តេច ប្រសិនបើពួកគេមិនចេះអាន និង សរសេរ។
- ធ្វើយ៉ាងណាឱ្យមានមនុស្សចូលរួមច្រើនបើអាចធ្វើទៅបាន។ នៅក្នុងបណ្តាប្រទេសក្រីក្រ ក្រុមស្ត្រីមានឥទ្ធិពលច្រើន ជាពិសេស ក្នុងសហគមន៍ក្រីក្រ។

**សូមកត់ចំណាំ:** (អ្នកអាចធ្វើបន្ថែម នៅក្នុងសកម្មភាពទាំងនេះ ដោយបិទផ្ទាំងរូបភាព ដែលមិនប្រាកដថា ជាអក្សរអ្វីនៅទីកន្លែងសាធារណៈ នៅក្នុងព្រឹត្តិការណ៍ថ្នាក់ជាតិ។ គោលបំណងនៃការធ្វើបែបនេះ ដើម្បីធ្វើឱ្យមនុស្សមានការពិបាករកកន្លែងធម្មតាឃើញ ដូចជា ការយល់ដឹងជាទូទៅ ដែលពួកគេមិនអាចអានផ្ទាំងរូបភាពនោះបាន)។

## ៤.៨. តើទីកន្លែងណាដែលយើងគួរធ្វើការផ្សព្វផ្សាយ នៅក្នុងសប្តាហ៍សកម្មភាពជាសកល ឆ្នាំ ២០០៩?

សូមចែកចាយសម្ភារៈផ្សព្វផ្សារឱ្យបានទូលំទូលាយតាមដែលអាចធ្វើបាន។ សូមធ្វើការទំនាក់ទំនងជាមួយសាលារៀន និងមជ្ឈមណ្ឌលសហគមន៍ឱ្យបានច្រើន។ ការស្នើសុំថវិកា សម្រាប់អ្នករៀបចំយុទ្ធនាការដែលធ្លាប់បានទទួលកន្លងមក នឹងនៅតែផ្តល់ជូន។ យើងសង្ឃឹមថា ឆ្នាំនេះនឹងមានក្រុមការងារមូលដ្ឋានច្រើនចូលរួម ហើយយើងសូមលើកទឹកចិត្តដល់អ្នក គិតនិងព្យាយាមធ្វើយ៉ាងឱ្យបានគ្រប់សាលា នៅក្នុងប្រទេសរបស់អ្នក។

ការសំណូមពរមួយទៀតគឺ ក្រៅពីការផ្ញើរព័ត៌មានទៅសាលា អ្នកគួរតែព្យាយាមចែកចាយតាមទីផ្សារក្នុងមូលដ្ឋាន ហាងលក់ទំនិញ និងអាគារជំនួញផ្សេងៗ។ អ្នកអាចធ្វើតាមរយៈអង្គការសាសនា និងក្រុមការងារផ្សេងៗ ដូចជា ក្រុមកុមារីនាំមុខ និង ស្កូត (Girl Guides and Boy Scouts)។ ពួកគេភាគច្រើនបច្ចុប្បន្នគាំទ្រ គោលដៅអភិវឌ្ឍសហស្សវត្ស (MDGs) និង ការអប់រំសម្រាប់ទាំងអស់គ្នា។ យើងត្រូវការឱ្យសង្គមគាំទ្រពីសារៈសំខាន់នៃការអប់រំសម្រាប់ទាំងអស់គ្នា ដូចនេះ បណ្តាញការងារណាមួយដែលមានចំនួនក្រុមដែលបានចងក្រងច្រើននៅក្នុងប្រទេស និង ចង់គាំទ្រលើគុណភាពនៃការអប់រំសម្រាប់ទាំងអស់គ្នាគឺមានប្រយោជន៍បំផុត ដើម្បីឱ្យពួកគេចូលរួមនៅក្នុងព្រឹត្តិការណ៍សម្រាប់ **ការអានដ៏ធំមួយ** ។ វាមានសារៈសំខាន់ផងដែរ ដើម្បីឱ្យឪពុកម្តាយ និង អាណាព្យាបាលចូលរួមនៅក្នុងសកម្មភាពទាំងនោះ។ នៅក្នុងកញ្ចប់ព័ត៌ដែលផ្ញើរទៅសាលា អ្នកអាចបញ្ចូលសារដែលសិស្សានុសិស្សគួរបង្រៀន និងអញ្ជើញឪពុកម្តាយឬអាណាព្យាបាលរបស់គេ ដើម្បីអានសៀវភៅរឿងនេះ!

បង្កើតចេញពីសកម្មភាពទាំងឡាយ ដែលមាននៅក្នុងសប្តាហ៍សកម្មភាពជាសកល ២០០៨ និងទីកន្លែងដែលអ្នកធ្វើការផ្សព្វផ្សាយពីយុទ្ធនាការ។ ប្រសិនបើអាចធ្វើបាន សូមព្យាយាម និងផ្តិតយកនូវសកម្មភាពណា ដែលអាចដាក់បញ្ចូលទៅក្នុងសកម្មភាពយុទ្ធនាការ ២០០៩ ។ សូមមើលទៅលើអ្វីដែលមាន

ដំណើរការល្អកន្លងមកនៅក្នុងប្រទេសរបស់អ្នក និងបន្ថែមសកម្មភាពនោះ ទៅលើតារាងសកម្មភាពសម្រាប់សប្តាហ៍សកម្មភាពជាសកល ២០០៩។

### ៤.៩. តើនៅពេលណា យើងនឹងផ្សព្វផ្សាយពីសប្តាហ៍សកម្មភាព យុទ្ធនាការជាសកល សម្រាប់ការអប់រំសម្រាប់ទាំងអស់គ្នា?

សប្តាហ៍សកម្មភាព យុទ្ធនាការជាសកលសម្រាប់ការអប់រំសម្រាប់ទាំងអស់គ្នា នឹងចាប់ផ្តើមពីថ្ងៃទី **២០-២៦ ខែមេសា ឆ្នាំ២០០៩**។ ទោះជាយ៉ាងណាក៏ដោយ ដូចឆ្នាំមុនៗដែរ ប្រសិនបើសប្តាហ៍នេះ មានការលំបាកក្នុងការរៀបចំ នោះអ្នកអាចធ្វើក្នុងសប្តាហ៍ផ្សេងទៀតនៅក្នុងប្រទេសរបស់អ្នក។

### ៤.១០. តើយើងត្រូវធ្វើការទំនាក់ទំនងជាមួយអ្នកសារព័ត៌មានដោយរបៀបណា?

វាមានសារៈសំខាន់ណាស់ដើម្បីធានាថា ព្រឹត្តិការណ៍មួយចំនួនធំដែលបានរៀបចំ ត្រូវបានធ្វើជាសាក្សីតាមរយៈសារព័ត៌មាន។ ការងារនេះមានសារៈសំខាន់ព្រោះវាធ្វើឱ្យអ្នកនយោបាយមានការធានា និងរក្សាការសន្យារបស់ខ្លួន។ វាក៏អាចធានាផងដែរថា សកម្មភាពដែលបានដល់អ្នកស្តាប់បានទូលំទូលាយ។ យើងនឹងផ្ញើរកញ្ចប់សម្ភារៈទំនាក់ទំនង នៅក្នុងខែមករា ដោយមានជូននូវគំនិតយោបល់ច្រើនដើម្បីធ្វើការជាមួយនឹងអ្នកសារព័ត៌មាន ប៉ុន្តែជាគោលយើងស្នើថា:

ចំពោះព្រឹត្តិការណ៍យុទ្ធនាការថ្នាក់ជាតិ សូមព្យាយាម និងអញ្ជើញអ្នកសារព័ត៌មានឱ្យបានច្រើនតាមដែលអាចធ្វើបាន។ ប្រសិនបើអ្នកមានលទ្ធភាពអញ្ជើញប្រមុខរដ្ឋ ឬក៏រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ទៅចូលរួមនៅក្នុងព្រឹត្តិការនោះ អ្នកគួរតែអញ្ជើញអ្នកសារព័ត៌ទៅទីនោះដែរ។ នៅក្នុងកញ្ចប់ព័ត៌មានផ្ញើរទៅសាលាសូមលើកទឹកចិត្តដល់ពួកគេ ដើម្បីអញ្ជើញអ្នកសារព័ត៌មានក្នុងមូលដ្ឋាន ដើម្បីធ្វើជាសាក្សី ចំពោះការចូលរួមរបស់អ្នកនយោបាយនៅក្នុងព្រឹត្តិការណ៍ **ការអានដ៏ធំមួយ** ។

សូមធ្វើឱ្យប្រាកដថា អ្នកបានដឹងគ្រប់ផ្នែកដែលពាក់ពន្ធ័ទាំងអស់ និងឱកាសផ្សេងៗនៅក្នុងការផ្សព្វផ្សាយពត៌មានក្នុងមូលដ្ឋានរបស់អ្នក។ ការសែតក្នុងមូលដ្ឋានរបស់អ្នក វិទ្យុ ឬ ទូរទស្សន៍ នឹងមានចន្លោះ

ទំនេរដែលអ្នកយកអត្ថប្រយោជន៍នេះ ពិចារណារកអាគារលក់ទំនិញផ្សេងៗនៅក្នុងតំបន់ ដែលអាចជួយអ្នកក្នុងការចំណាយ សម្រាប់ការផ្សាយព័ត៌មាន ដើម្បីធ្វើឱ្យមានការផ្សព្វផ្សាយទ្រង់ទ្រាយធំ ។

យើងនឹងផលិតសម្ភារៈមួយចំនួនផងដែរ ដោយមានកិច្ចសម្ភាសន៍ជាមួយអ្នកនិពន្ធ និងអ្នកតស៊ូមតិសំខាន់ៗលើការងារអប់រំ ដែលបានសរសេររឿងសម្រាប់សៀវភៅ ។ ដោយការប្រើប្រាស់សម្ភារៈទាំងអស់នេះ អ្នកសារព័ត៌មាន ជាពិសេស ស្ថានីវិទ្យុសហគមន៍ និងអ្នកស្តាប់វិទ្យុ នឹងមានលទ្ធភាពចូលរួមនៅក្នុងព្រឹត្តិការណ៍ **ការអានដ៏ធំមួយ** ដោយផ្ទាល់ ជាជាងការមិនបានទទួលព័ត៌មានពីព្រឹត្តិការណ៍ ។ ព័ត៌មានបន្ថែមនឹងត្រូវបានផ្តល់ជូននៅក្នុងកញ្ចប់ធនធាន និងកញ្ចប់សម្ភារៈប្រាស្រ័យទាក់ទង ។

### ៤.១១. តើសៀវភៅរឿងមានប្រយោជន៍ដោយរបៀបណា?

បច្ចុប្បន្ន យើងកំពុងរៀបចំផែនការបញ្ចប់ សម្រាប់សៀវភៅរឿង ហើយព័ត៌មានជាច្រើនទៀតនឹងមាននៅក្នុងកញ្ចប់ធនធាន ។ គោលគំនិតសំខាន់ គឺថាយើងនឹងផ្តល់សាច់រឿងជាសកលខ្លះៗ អំពីអ្នកនិពន្ធ និងអ្នកតស៊ូមតិល្បីៗ នៅលើពិភពលោក ។ រឿងទាំងអស់នេះនឹងរួមផ្សំជាមួយនឹងរឿងប្រឌិត ការផ្តល់បទពិសោធន៍ផ្ទាល់ខ្លួនលើឥទ្ធិពលពីការអប់រំ និងការសម្ភាសន៍ជាមួយនឹងកុមារ និងមនុស្សពេញវ័យដែលមិនចេះអក្សរ ។ សាច់រឿងទាំងអស់នេះនឹងត្រូវធ្វើការបកប្រែទៅក្នុងភាសាមួយយ៉ាងសមរម្យ ហើយអ្នកមានឱកាសបន្ថែមសាច់រឿងពីអ្នកនិពន្ធល្បីៗ និងអ្នកតស៊ូមតិលើការងារអប់រំនៅក្នុងប្រទេសរបស់អ្នក ។ នៅចុងឆ្នាំ២០០៨ យើងនឹងផ្តល់គំរូនៃការសរសេរលិខិត និងឈ្មោះផ្សេងៗ ដល់ក្រុមអ្នករៀបចំយុទ្ធនាការថ្នាក់ជាតិ ។ បន្ទាប់មក អ្នករៀបចំយុទ្ធនាការថ្នាក់ជាតិ អាចទំនាក់ទំនងជាមួយមនុស្សណាម្នាក់ ដែលអ្នកចង់សរសេរពីគេ ដើម្បីដាក់ក្នុងសៀវភៅនេះ ។ នៅពេលដែលមានការបញ្ជាក់ច្បាស់លាស់ សាច់រឿងនៅថ្នាក់ជាតិ និងនៅលើពិភពលោក នឹងធ្វើការបញ្ចូលគ្នាដើម្បីបង្កើតជាសៀវភៅមួយនៅក្នុងប្រទេសរបស់អ្នក ។

នេះមានន័យថា ប្រទេសនីមួយៗនឹងមានសៀវភៅរឿងផ្សេងៗគ្នា ប៉ុន្តែវានឹងមានវត្ថុធាតុរួមមួយ ។ ការណែនាំជុំវិញ **ការអានដ៏ធំមួយ** នឹងមានភាពបត់បែនច្រើនជាងសប្តាហ៍សកម្មភាពឆ្នាំមុនៗ ដូច្នេះ យើងមិនចាំបាច់ត្រូវប្រើប្រាស់សៀវភៅដូចគ្នាទាំងស្រុងនោះទេ ។

**៤.១២. តើសៀវភៅរឿងនោះមានទម្រង់ទ្រាយយ៉ាងដូចម្តេច? ហើយនឹងធ្វើការបោះពុម្ពដោយរបៀបណា?**

សៀវភៅរឿងនេះ ជាសៀវភៅរឿងមួយដែលអ្នកអាចបន្ថែមរឿងរបស់អ្នកផ្ទាល់ ដើម្បីផលិត ថតចម្លង ផ្ញើរតាមទូរសារ ឬ អ៊ីម៉ែល។ វាអាចជាសៀវភៅមួយដាក់នៅលើវែបសាយ ដែលមនុស្សគ្រប់រូបនៅទូទាំងពិភពលោកអាចអានបានតាមរយៈ អ៊ីនធឺណែត និងបន្ថែមឈ្មោះរបស់គេ។ សៀវភៅនោះក៏មានផងដែរ ជាទម្រង់សម្រាប់ក្រុមរៀបចំយុទ្ធនាការថ្នាក់ជាតិ ដើម្បីធ្វើការបោះពុម្ព និងផ្សព្វផ្សាយនៅថ្នាក់ជាតិ ដូចនេះសូមដាក់ទៅក្នុងផែនការរបស់អ្នក។

## ៥. ធនធានដែលនឹងទទួលបានពីយុទ្ធនាការជាសកលសម្រាប់ការអប់រំ

កញ្ចប់ផែនការត្រូវបានរៀបចំឡើងដើម្បីជួយអ្នក ក្នុងការចាប់ផ្តើមរៀបចំឯកសារសម្រាប់សកម្មភាពសប្តាហ៍ជាសកល និងក្នុងគោលបំណងសម្រេចបានការចូលរួមច្រើនពីមន្ត្រីរបស់រដ្ឋាភិបាល អ្នកដឹកនាំសហគមន៍ បណ្តាញព័ត៌មាន អ្នកមានឈ្មោះល្បីល្បាញ មាតាបិតា និងគំនិតរបស់ថ្នាក់ដឹកនាំសហគមន៍ផ្សេងៗ។ ក្រៅពីកញ្ចប់ផែនការ គណៈកម្មាធិការរៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំ នឹងផ្ញើរជូននូវឯកសារពីរសំខាន់ផ្សេងទៀត ដើម្បីជួយដល់ការងាររបស់អ្នក:

**ក)** កញ្ចប់ឯកសារសម្រាប់សកម្មភាពសប្តាហ៍នៃយុទ្ធនាការជាសកលសម្រាប់ការអប់រំ (ចុងខែកញ្ញា ២០០៨) កញ្ចប់ឯកសារនេះ នឹងមានផ្ទាប់ជូននូវធនធានផ្សេងៗមួយចំនួន ហើយឯកសារទាំងអស់នោះមានភាពងាយស្រួលធ្វើការកែសម្រួលទៅតាមស្ថានភាពជាក់ស្តែង ទៅនឹងបរិបទនៅក្នុងតំបន់របស់អ្នក:

- ករណីសិក្សា (ប្រសិនបើមាន ជួយផ្ញើរជូនមកគណៈកម្មាធិការរៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំ) និងការរៀបចំផែនការពតិមានផ្សព្វផ្សាយ
- ឯកសារសង្ខេប ស្តីពីសប្តាហ៍សកម្មភាពជាសកល
- ការណែនាំនូវរបៀបប្រើប្រាស់កូនសៀវភៅ
- ទម្រង់បញ្ជាក់ពីសុពលភាព (Validation Form)
- សម្ភារៈផ្សេងៗ ស៊ីឌី ជាមួយផ្ទាំងរូបភាព និង រូបឃីហោនានា (posters and logos)
- គំនិតផ្សេងៗស្តីពីការរៀបចំយុទ្ធនាការ
- គំរូលិខិតសម្រាប់អញ្ជើញអ្នកមានឈ្មោះល្បីល្បាញណាម្នាក់

ខ) កញ្ចប់ឯកសារទំនាក់ទំនងសម្រាប់សកម្មភាពសប្តាហ៍ជាសកល (នៅចុងខែមករា ២០០៩)

កញ្ចប់ឯកសារនេះរួមមាន:

- សៀវភៅរឿង
- កញ្ចប់ព័ត៌មាន ជាមួយនឹងព័ត៌មានពិស្តារស្តីពីហេតុការណ៍ជាក់ស្តែង និង ស្ថិតិផ្សេងៗ
- ការដកស្រង់ពាក្យសម្តី និងហត្ថលេខាផ្សេងៗ ដែលអ្នកអាចប្រើបាន
- គំរូ នៃការចេញផ្សាយព័ត៌មាន
- ការរៀបចំបដាតាម វិទ្យុ និងសកម្មភាពនានាដែលពាក់ព័ន្ធ
- ទំព័រ វិទ្យុ
- គំរូសម្រាប់សរសេរលិខិតថ្លែងអំណរគុណ

## ៦. ការស្នើសុំក្នុងការបង្កើតគោលនយោបាយ និងការទាមទារផ្សេងៗ

យើងត្រូវធ្វើសកម្មភាពទៅតាមអ្វីដែលយើងបានធ្វើនៅក្នុងយុទ្ធនាការកន្លងមក។ ការអប់រំគឺជាសិទ្ធិមនុស្សហើយសិទ្ធិនេះត្រូវបានទទួលស្គាល់នៅក្នុងឯកសារស្តីពីសិទ្ធិមនុស្សមួយចំនួនផ្សេងទៀត។ ច្បាប់ទាំងអស់នេះ បានសម្រេចលើអត្ថន័យយ៉ាងទូលំទូលាយ ដោយការធ្វើឱ្យល្អិតល្អន់នៃទិសដៅអប់រំសម្រាបទាំងអស់គ្នាដោយរដ្ឋាភិបាលនៅឯសន្និសីទពិភពលោកស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា នៅទីក្រុងដាកានាឆ្នាំ២០០០។ ជាពិសេស សប្តាហ៍សកម្មភាពឆ្នាំនេះនឹងផ្តោតលើទិសដៅទី ៤ នៃការអប់រំសម្រាប់ទាំងអស់គ្នា — បង្កើនការចេះអាន និងសរសេររបស់មនុស្សពេញវ័យឱ្យបាន ៥០%។ ក្រុមអ្នករៀបចំយុទ្ធនាការទាំងអស់ត្រូវបានស្នើសុំឱ្យពិនិតមើលទៅលើគោលដៅទាំងអស់នេះ ដែលយើងប្រើជាម៉ែត្រសម្រាប់វាស់វែងលើការសម្រេចបានរបស់រដ្ឋាភិបាល ការទាមទារជាក់លាក់ទាំងអស់នោះត្រូវតែបានធ្វើឡើងពី: ក) ប្រទេសកំពុងអភិវឌ្ឍ ខ) ប្រទេសម្ចាស់ជំនួយ និង គ) ស្ថាប័នអន្តរជាតិ។

**រដ្ឋាភិបាលដែលនៅក្នុងបណ្តាប្រទេសក្រីក្រគួរតែ:**

**១,** បង្កើតខចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដែលចែងអំពីអក្ខរកម្មរបស់មនុស្សពេញវ័យ ការអប់រំរបស់មនុស្សពេញវ័យ និងយុវជន គឺជាសិទ្ធិទទួលបានរបស់ពួកគេ ដោយផ្សារភ្ជាប់ជាមួយនឹងសិទ្ធិសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងការរើសអើងក្នុងការអប់រំ។

**២,** បង្កើនថវិកាដើម្បីធានាថា យ៉ាងហោចណាស់ ៣% នៃថវិកាអប់រំត្រូវចំណាយទៅលើអក្ខរកម្មរបស់មនុស្សពេញវ័យ។

**៣,** ពង្រីកផែនការវិស័យ ដើម្បីបញ្ចូលឧបសគ្គទាំងពីរ អក្ខរកម្ម និង គុណភាណនៃការអប់រំ ឬធ្វើឱ្យរឹងប៉ឹងឡើងវិញលើផែនការអប់រំសម្រាប់ទាំងអស់គ្នាដែលមានស្រាប់ និង យន្តការនានាដែលបានបង្កើតឡើងក្នុងចន្លោះឆ្នាំ ២០០០ និង ២០០២។

**ប្រទេសអ្នកមាន និងស្ថាប័នអន្តរជាតិគួរតែៈ**

១. ពន្យារអាណត្តិ លើគំនិតផ្តួចផ្តើមនៃការអប់រំសម្រាប់ទាំងអស់គ្នា ប្រយោជន៍ដើម្បីឱ្យមានការលើកទឹកចិត្តដល់បណ្តាប្រទេសទាំងនោះ ដើម្បីធ្វើការដោះស្រាយទិសដៅទាំង៦ នៃការអប់រំសម្រាប់ទាំងអស់គ្នា ដែលបញ្ជាក់ពិសេសលើ អក្ខរកម្ម ជាចំបង។

២. បង្កើនមូលដ្ឋានចំណេះដឹងលើការអប់រំ តាមរយៈធ្វើការបង្រួបបង្រួម ដើម្បីប្រមូលទិន្នន័យលើក៏រិត អក្ខរកម្ម ក៏ដូចជាបង្កើតការសិក្សាវិភាគ លើផលប៉ះពាល់នៃអក្ខរកម្ម។

៣. បង្កើន និងធានាការអាចព្យាករបានអំពីជំនួយដល់ អក្ខរកម្ម ជាបញ្ហាមួយអាទិភាព និងផ្តល់ថវិកាពេញលិញចំពោះចំណែកនៃការចូលរួមរបស់គេ នៃទឹកប្រាក់១៦ពាន់លានដុល្លា ដែលត្រូវការសម្រាប់ការអប់រំសម្រាប់ទាំងអស់គ្នា រួមទាំងការចូលរួមរបស់គេ នៃទឹកប្រាក់ ១ ពាន់លានដុល្លា ដែលត្រូវការសម្រាប់ អក្ខរកម្ម មនុស្សពេញវ័យ។

៤. បង្កើតយន្តការកែសម្រួលផ្នែកហិរញ្ញវត្ថុ ដើម្បីផ្តល់ថវិកាដល់កម្មវិធីអក្ខរកម្មយុវជន និងមនុស្សពេញវ័យ ក្នុងបណ្តាប្រទេសទាំងនោះ ដែលត្រូវការកម្មវិធីទាំងនេះជាចំបង។

## ៧, តារាងពេលវេលា

| | |
|---|---|
| ខែកញ្ញា | កញ្ចប់សម្ភារៈសម្រាប់សប្តាហ៍សកម្មភាព នឹងត្រូវបានផ្ញើរជូនទៅក្រុមរៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំ ដែលបានចុះបញ្ជីឈ្មោះ |
| ចុងខែកញ្ញា/ដើមខែតុលា | យើងស្នើសុំឱ្យមានកិច្ចប្រជុំរៀបចំផែនការថ្នាក់ជាតិមួយដើម្បីៈ<br>- រៀបចំបង្កើតគណៈកម្មការសប្តាហ៍សកម្មភាពថ្នាក់ជាតិ<br>- ជ្រើសរើសអង្គការសំរាប់ធ្វើការសំរបសំរួលថ្នាក់ជាតិ<br>- កំណត់អ្នកសំរបសំរួល/ជនបង្គោលសម្រាប់រៀបចំយុទ្ធនាការអប់រំ<br>- ព្រមព្រៀងគ្នា តើសកម្មភាពជាសកលណាខ្លះ អ្នកនឹងចូលរួម<br>- ធ្វើផែនការ តើសំភារៈអ្វីខ្លះដែលអ្នកចង់ផលិតនៅក្នុងស្រុក (ផ្ទាំងរូបភាព ខិតបណ្ណ័ ។ល។) ហើយនណាជាអ្នកធ្វើការងារនេះ? |
| នៅថ្ងៃទី៨ ខែតុលា | បន្ទាប់ពីកិច្ចប្រជុំ អង្គការសំរបសំរួល/ជនបង្គោលសម្រាប់យុទ្ធនាការជាសកលសម្រាប់ការអប់រំ គួរតែចុះបញ្ជីជាមួយនឹងយុទ្ធនាការជាសកលសំរាប់ការអប់រំ (GCE) ដោយបំពេញទម្រង់បែបបទចុះឈ្មោះ ឬ ផ្ញើរ តាមអ៊ីម៉ែល actionweek@campaignforeducation.org ទំរង់បែបបទចុះឈ្មោះត្រូវបញ្ចូលព័ត៌មានពិស្តារពី **សម្ភារៈ និងទម្រង់ដាក់ពាក្យស្នើរសុំថវិកា**។ ថវិកាសម្រាប់ផលិតសម្ភារៈគឺមានចំនួនកំណត់ និងមានសម្រាប់តែក្រុមការងាររៀបចំយុទ្ធនាការនៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍតែប៉ុណ្ណោះ។ ថវិកាផ្តល់ជូនតែក្រុមការងារនៅក្នុងបណ្តាប្រទេសក្នុងតំបន់អាស៊ី ដែលបានបំពេញនូវតម្រូវការនៃការដាក់ពាក្យសុំ។ |
| ខែវិច្ឆិការ | គណៈកម្មាធិការរៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំ ផ្ញើរព័ត៌មានពិស្តារពីសៀវភៅរឿង និង គំរូលិខិត ដែលអាចឱ្យក្រុមការងាររៀបចំយុទ្ធនាការ |

| | |
|---|---|
| | ថ្នាក់ជាតិមានលទ្ធភាព ចង់សរសេរ ឬក៏លើកឡើងពីតួរលេខថ្នាក់ជាតិ ដើម្បីសរសេររឿងមួយនៅក្នុងសៀវភៅនោះ។ |
| ចុងខែវិច្ឆិការ/ដើមខែធ្នូ | យើងសំណូមពរឱ្យកិច្ចប្រជុំរៀបចំផែនការថ្នាក់ជាតិ ឈានដល់ការព្រមព្រៀងគ្នាលើសកម្មភាពដែលត្រូវអនុវត្ត និងអនុមតិលើសម្ភារៈដែលត្រូវផលិត ហើយនិងការកែសម្រួលសម្ភារៈ និងការបកប្រែសម្ភារៈសំរាប់យុទ្ធនាការជាសកលសម្រាប់ការអប់រំ។ កំណត់ពេលវេលា និងកាលបរិច្ឆេតសម្រាប់ព្រឹត្តិការណ៏ថ្នាក់ជាតិ។ |
| ថ្ងៃទី១០ ខែធ្នូ | ជាពេលវេលាកំណត់ ដែលត្រូវផ្ញើរគំរោងស្នើសុំថវិកាសម្រាប់សប្តាហ៏សកម្មភាពជាសកល និង ថវិកាសម្រាប់ផលិតសម្ភារៈ។ |
| ថ្ងៃទី១៥ ខែមករា | គណៈកម្មាធិការរៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំ ផ្តល់ព័ត៌មានពីលទ្ធផលនៃផ្តល់ថវិកាសម្រាប់យុទ្ធនាការ។ |
| ខែមករា | យើងស្នើរសុំឱ្យមានកិច្ចប្រជុំរៀបចំផែនការថ្នាក់ជាតិមួយទៀតដើម្បីៈ<br>- ទទួលបញ្ជីរាយនាមសាលារៀន/ក្រុមធ្វើការងារអប់រំទាំងអស់ នៅក្នុងប្រទេសរបស់អ្នក និងព្រមព្រៀងធ្វើលិខិតរួមគ្នាមួយ។ សរសេរលិខិតទៅគ្រប់សាលារៀននៅក្នុងប្រទេសរបស់អ្នក ធ្វើការកែសម្រួលលើសម្ភារៈទទួលបានពី គណៈកម្មាធិការរៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំដែលអ្នកយល់ថាសមស្រប។<br>- រៀបចំតារាងបែងចែកការងារមួយ និងបញ្ជាក់ពីការទទួលខុសត្រូវ ដាក់ឈ្មោះបុគ្គលដែលទទួលការងារនិមួយៗ។<br>- ប្រសិនបើអ្នករៀបចំព្រឹត្តិការថ្នាក់ជាតិ សូមរួមគ្នារៀបចំលិខិតអញ្ជើញទៅប្រមុខរដ្ឋ ឬក៏រដ្ឋមន្ត្រីហិរញ្ញវត្ថុ។ |

| | |
|---|---|
| | - ព្រមព្រៀងទៅលើបញ្ជីរាយនាមអ្នកនយោបាយសំខាន់ៗ អ្នកដឹកនាំសហគមន៍ អ្នកនាំពាក្យ និងបុគ្គលដែលមានឈ្មោះល្បីផ្សេងទៀត ដែលអ្នកសង្ឃឹមថាឱ្យពួកគេចូលរួម និងធ្វើការបែងចែកភារកិច្ច សម្រាប់ធ្វើការទំនាក់ទំនងជាមួយពួកគេ។ |
| ខែកុម្ភៈ | ផ្ញើរសម្ភារៈទៅរោងពុម្ព បន្ទាប់មកផ្ញើរទៅសាលារៀន និងក្រុមការងារផ្សេងទៀត។ រួមទាំងសម្ភារៈសម្រាប់រៀបចំយុទ្ធនាការថ្នាក់ជាតិ និងសម្ភារៈសម្រាប់រៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំ ដែលអ្នកបានជ្រើសរើសដើម្បីធ្វើការកែសម្រួលសៀវភៅរឿង នឹងត្រូវធ្វើការបោះពុម្ភនៅពេលនេះ ទោះបីជាការរៀបចំសម្រាប់ធ្វើការបោះពុម្ភនឹងត្រូវផ្តល់នៅពេលក្រោយក៏ដោយ។ |
| ខែកុម្ភៈ | ផ្ញើរលិខិតអញ្ជើញទៅប្រមុខរដ្ឋ/រដ្ឋមន្ត្រីសំខាន់ៗ/បុគ្គលមានឈ្មោះល្បី និងរៀបចំឱ្យមានសកម្មភាពជាក់លាក់ដើម្បីគាំទ្រទៅដល់ប្រធានបទប្រចាំឆ្នាំ។ |
| ខែកុម្ភៈ | ជាពេលវេលាដ៏ល្អសម្រាប់រដ្ឋ/ស្រុក/រៀបចំកិច្ចប្រជុំមូលដ្ឋាន នៅពេលដែលសម្ភារៈពស្តុភារ និងយន្តការសម្របសម្រួល ត្រូវបានដោះស្រាយនៅថ្នាក់ជាតិ។ |
| ដើមខែមីនា | អញ្ជើញប្រពន្ធ័ផ្សព្វផ្សាយ ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយ !! |
| ខែមីនា | យើងស្នើរសុំឱ្យមានកិច្ចប្រជុំរៀបចំផែនការថ្នាក់ជាតិមួយទៀត ដើម្បីរៀបចំយុទ្ធសាស្រ្តព័ត៌មាន ថាតើអ្នកយកព័ត៌មានមួយណាដែលត្រូវអញ្ជើញ និងនណាជាអ្នកធ្វើការទំនាក់ទំនង? តើសម្ភារៈអ្វីខ្លះ (ការចេញផ្សាយព័ត៌មាន របាយការណ៍ ការសង្ខេបឯកសារ ។ល។) ដែលត្រូវការ នរណាជាអ្នកសរសេរ និង ផលិតសម្ភារៈទាំងអស់នោះ? |
| ចុងខែមីនា/ ដើមខែមេសា | ការជម្រុញចុងក្រោយ - ប្រើគ្រប់មធ្យោបាយទាំងអស់ ដើម្បីរំឭកអ្នកគ្រប់គ្នាអំពីសប្តាហ៏សកម្មភាព និងពង្រឹងភិមសា ផ្ញើរសារតាមទូរសព្ទ័ និយាយ |

| | |
|---|---|
| | ដោយផ្ទាល់មាត់ ការផ្សព្វផ្សាយតាមរយៈសហគមន៍ ហាងលក់ទំនិញក្នុងមូលដ្ឋាន ដើម្បីដាក់តាំងផ្ទាំងគំនូររូបភាពនៅក្នុងហាងលក់ទំនិញរបស់គេ ។ល។ សន្និសីទកិច្ច ការិយាល័យ យុទ្ធសាស្ត្រព័ត៌មាន ហើយនិយាយទៅកាន់អ្នកសារពតិមាន ដើម្បីរក្សាភិមសា។ |
| ថ្ងៃទី១៩ ខែមេសា | ធ្វើរចេញនូវការផ្សព្វផ្សាយព័ត៌មាន និងធ្វើការទំនាក់ទំនងដោយផ្ទាល់ជាមួយអ្នកសារព័ត៌មាន |
| ថ្ងៃទី២០-២៦ ខែមេសា | សកម្មភាពសប្តាហ៏ចាប់ផ្តើម ! |
| ចុងខែមេសា/<br>ដើមខែឧសភា | ធ្វើរបាយការណ៏សកម្មភាពសប្តាហ៏ |

## ៨, ទម្រង់បែបបទចុះឈ្មោះ

សូមផ្ញើរទម្រង់បែបបទចុះឈ្មោះទៅកាន់ ម៉ូលីយ៉ា វ៉ាណាន់យ៉ាន់ដា **(Muleya Mwananyanda)** អ្នកសម្របសម្រួលសប្តាហ៍សកម្មភាពជាសកល នៃយុទ្ធនាការជាសកលសម្រាប់ការអប់រំ តាមរយៈអ៊ីម៉ែល **actionweek@campaignforeducation.org** មុនថ្ងៃទី៨ ខែតុលា។

ទម្រង់បែបបទនេះត្រូវបានបំពេញ លុះត្រាណាតែមានកិច្ចប្រជុំជាមួយសមាជិករៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំនៅថ្នាក់ជាតិរួច។ កិច្ចប្រជុំនេះគួរតែពិភាក្សាអំពីលទ្ធភាពស្តីពីការរៀបចំព្រឹត្តិការណ៍ថ្នាក់ជាតិ សម្រាប់សកម្មភាពសប្តាហ៍ជាសកល នៃការរៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំឆ្នាំ ២០០៩ ហើយទម្រង់ខាងក្រោមគឺសម្រាប់បំពេញឈ្មោះអ្នកដែលបានចូលរួមពិភាក្សា។ អ្នកទំនាក់ទំនងសំខាន់ គួរតែជាមនុស្សដែលដឹកនាំក្នុងការទំនាក់ទំនងជាមួយនឹង គណៈកម្មាធិការរៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំ ស្តីពីសកម្មភាពសប្តាហ៍ ២០០៩។ គេនឹងទទួលព័ត៌មានថ្មីៗ ពីលេខាធិការដ្ឋានគណៈកម្មាធិការរៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំ ហើយនឹងផ្តល់ព័ត៌ដល់លេខាធិការដ្ឋានអំពីផែនការដែលត្រូវធ្វើនៅក្នុងប្រទេសរបស់គេ។

**ក) ឈ្មោះក្រុមរៀបចំយុទ្ធនាការៈ** ____________________________

**ខ) ឈ្មោះអង្គការដែលមានផែនការចូលរួមក្នុងសប្តាហ៍សកម្មភាព ២០០៩**

| | |
|---|---|
| **១,** | **២,** |
| **៣,** | **៤,** |
| **៥,** | **៦,** |
| **៧,** | **៨,** |
| **៩,** | **១០,** |
| **១១,** | **១២,** |

| | |
|---|---|
| ១៣. | ១៤. |
| ១៥. | ១៦. |
| ១៧. | ១៨. |
| ១៩. | ២០. |

គ) ឈ្មោះ និងអ៊ីម៉ែល/លេខទូរសព្ទ័នៃអ្នកទំនាក់ទំនងសំខាន់ សម្រាប់សប្តាហ៍សកម្មភាព ២០០៩

(សូមបន្ថែមឈ្មោះទៀត ប្រសិនបើចាំបាច់)

| ឈ្មោះ | អង្គការ | អ៊ីម៉ែល | លេខទូរសព្ទ័/ទូរសារ |
|---|---|---|---|
| ក | | | |
| ខ | | | |
| គ | | | |

**ឃ) យើងនឹង ,,, (សូមគូសក្នុងប្រអប់ដែលសមស្រប)**

| | |
|---|---|
| រៀបចំ "**ព្រឹត្តិការណ៍ថ្នាក់ជាតិ**" នៅក្នុងសប្តាហ៍សកម្មភាព ២០០៩ នៅក្នុងសាលា និង ជាមួយក្រុមដទៃទៀត នៅទូទាំងប្រទេស ។ | បាទ/ចាំស ☐<br>ទេ ☐ |
| មានបំណង រៀបចំព្រឹត្តិការណ៍ថ្នាក់ជាតិ ដោយមានការចូលរួមពីប្រមុខរដ្ឋ ឬរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ | បាទ/ចាំស ☐<br>ទេ ☐ |

**ង) ការផ្តល់ថវិកា**

| | |
|---|---|
| យើងសូមស្នើសុំថវិកាសម្រាប់ផលិតសម្ភារៈចំនួន (ច្រើនបំផុត៨00 អ៊ឺរ៉ូ) សូមកត់សំគាល់ថា ដោយសារថវិកាមានចំនួនកំណត់ (ការស្នើសុំថវិកាសម្រាប់ផលិតសម្ភារៈនឹងត្រូវផ្តល់ដល់បណ្តាប្រទេសដែលកំពុងអភិវឌ្ឍតែប៉ុណ្ណោះ) | បាទ/ចាំស ☐<br>ទេ ☐ |
| យើងស្នើសុំថវិកាសម្រាប់ផ្ញើរឯកសារទៅតាមសាលារៀន (ចំនួនថវិកាពិតប្រាកដនឹងត្រូវ ធ្វើការបញ្ជាក់ (ចំនួនពិតប្រាកដនឹងត្រូវជម្រាបជូន — ប្រមាន ៣00 អ៊ឺរ៉ូ) ។ ថវិកា ទាំងអស់នេះចំណាយលើការផ្ញើរលិខិតទៅសាលារៀន និងក្រុមដទៃទៀត ដើម្បីអញ្ជើញ ពួកគេចូលរួមក្នុង វេទិការ **ការអានដ៏ធំមួយ** ។ | បាទ/ចាំស ☐<br>ទេ ☐ |
| យើងចង់ដាក់ពាក្យសុំថវិកាសម្រាប់សប្តាហ៍សកម្មភាពជាសកល ។ សូមផ្ញើរទម្រង់បែបបទ ស្នើសុំថវិកាជូនត្រឡប់មកវិញឱ្យបានមុនថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២00៨ ។ សូមបញ្ជាក់ថា ដោយសារថវិកាមានកំណត់ គណៈកម្មាធិការរៀបចំយុទ្ធនាការជាសកលសម្រាប់ការអប់រំ ទទួលតែឯកសារដាក់ពាក្យសុំណាផ្ញើរមកពីប្រទេសកំពុងអភិវឌ្ឍ តែប៉ុណ្ណោះ ។ | បាទ/ចាំស ☐<br>ទេ ☐ |

**ច) សូមមេត្តាប្រាប់ អំពីអាស្រ័យដ្ឋានដែលត្រូវផ្ញើរឯកសារសម្រាប់សប្តាហ៍សកម្មភាព ២០០៩**

<table>
<tr><th>ឈ្មោះទំនាក់ទំនង</th><th colspan="3">ទូរសព្ទ័ទំនាក់ទំនង</th><th>ឈ្មោះអង្គការ បើមាន</th></tr>
<tr><td></td><td>លេខកូដរបស់ប្រទេស</td><td>លេខកូដរបស់ទីក្រុង</td><td>លេខទូរសព្ទ័</td><td></td></tr>
<tr><td colspan="5">អាស្រ័យដ្ឋានផ្លូវ ទី ១</td></tr>
<tr><td colspan="5">អាស្រ័យដ្ឋានផ្លូវ ទី ២</td></tr>
<tr><td colspan="3">ស្រុក/ទីក្រុង</td><td>លេខប្រអប់សំបុត្រ</td><td>ប្រទេស</td></tr>
</table>

* លេខទូរសព្ទ័ទំនាក់ទំនងត្រូវការជាចាំបាច់ សម្រាប់អ្នករត់សំបុត្រនៅពេលត្រូវប្រគល់សម្ភារៈ។ សូមផ្តល់លេខប្រអប់សំបុត្រ។ សេវាកម្មរត់សំបុត្រមិនអាចទំលាក់ទៅតាមប្រអប់សំបុត្របានទេ។